ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

លេខ : ០០២ ដនស.សរ

# សារាចរ

## ស្តីពី

## ឆ្លាតម្លាតអគារ និងលិខិតអនុញ្ញាតសាងសង់ ក្រោមសមត្ថកិច្ចអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ ឱ្យមានតម្លាភាព និងភាពងាយស្រួលក្នុងការអនុវត្ត អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា ៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងអនុក្រឹត្យលេខ ២២៤ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០ ស្តីពីលិខិតអនុញ្ញាតសាងសង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ដ.ន.ស.) សូមធ្វើការណែនាំដូចខាងក្រោម÷

### ក. ឆ្លាតម្លាតអគារ ក្នុងរាជធានី ក្រុង និងទីប្រជុំជន

១. ចំពោះទីតាំងមានប្លង់ឆ្លាតម្លាតស្រាប់ដែលបានអនុវត្តរួច បទប្បញ្ញត្តិប្រើប្រាស់ដីត្រូវកំណត់ឆ្លាតម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ ត្រូវអនុវត្តស្របតាមប្លង់តម្រង់ជួរដែលមានស្រាប់ ឬតាមផែនការប្រើប្រាស់ដី ដែលបានធ្វើការព្យាករណ៍អំពីលទ្ធភាពពង្រីកផ្លូវនាពេលអនាគត។

២. ចំពោះទីតាំងដែលពុំមានប្លង់ឆ្លាតម្លាត បទប្បញ្ញត្តិប្រើប្រាស់ដីត្រូវកំណត់ឆ្លាតម្លាតអគារក្នុងដីឡូត៍ពីព្រំដីកាន់កាប់ស្របច្បាប់ ត្រូវអនុវត្តស្របតាមការកំណត់ដូចខាងក្រោម÷

#### ២.១. ចំពោះអគារដែលមានកម្ពស់ចាប់ពីជាន់ផ្ទាល់ដី ដល់ជាន់ទី៨

- ឆ្លាតម្លាតខាងមុខ ឬគម្លាតជាប់ផ្លូវ យ៉ាងតិច ៤ (បួន) ម៉ែត្រ។ ក្នុងករណីចាំបាច់ក្នុងតំបន់ពាណិជ្ជកម្ម និងតំបន់ចម្រុះ និងក្នុងករណីសំណង់គ្មានជញ្ជាំង មានតែសសរ ហើយជាន់ផ្ទាល់ដីត្រូវបានប្រើប្រាស់សម្រាប់ថ្មើរជើងសាធារណៈ គម្លាតនេះអាចកំណត់យ៉ាងតិច ២ (ពីរ) ម៉ែត្រ។
- ឆ្លាតម្លាតខាងក្រោយ យ៉ាងតិច ២ (ពីរ) ម៉ែត្រ។
- ឆ្លាតម្លាតចំហៀងសងខាងត្រូវរក្សាទុកយ៉ាងតិច ២ (ពីរ) ម៉ែត្រ។ ក្នុងករណីក្បាលដីមានប្រវែងតិចជាង ២០ ម៉ែត្រ ឆ្លាតម្លាតសងខាងអាចត្រូវបានអនុញ្ញាតឱ្យនៅត្រឹម ១០% នៃប្រវែងក្បាលដី។ ចំពោះសំណង់លំនៅឋាន ក្នុងករណីក្បាលដីដែលមានប្រវែងតិចជាង ១០ម៉ែត្រ ត្រូវរក្សាឆ្លាតម្លាតសងខាងយ៉ាងតិច ១ (មួយ) ម៉ែត្រ និងក្នុងករណីឆ្លាតម្លាត ១ (មួយ) ម៉ែត្រ មិនអាចរក្សាទុកបាន ដោយផ្អែកទៅតាមស្ថានភាពជាក់ស្តែងនៃក្បាលដី អាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិអនុញ្ញាតឱ្យសាងសង់ជាប់ព្រំតែម្តង។

អាសយដ្ឋាន : ដីឡូត៍លេខ ២០០៥ ផ្លូវលេខ ៣០៧ សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ
ទូរស័ព្ទ (855) 23 886 999 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

- ចំពោះសំណង់ដែលស្ថិតនៅក្នុងតំបន់លំនៅឋានជាប់គ្នា ត្រូវរក្សាគម្លាតអប្បបរមាជាប់ផ្លូវ ៤ (បួន) ម៉ែត្រ ឬរក្សាតាមជួរតម្រង់ កម្ពស់ និងរចនាបថដូចអគារស្របច្បាប់ជិតខាងដែលមានស្រាប់ ហើយអាចសាងសង់ជាប់ព្រំ ឬជញ្ជាំងអឡុសិទ្ធិ ដោយម្ចាស់សំណង់ត្រូវទទួលខុសត្រូវ នូវរាល់ផលប៉ះពាល់អគារអ្នកជិតខាង ដែលបណ្ដាលមកពីការសាងសង់អគាររបស់ខ្លួន ដោយត្រូវជួសជុល ឬសាងសង់ឡើងវិញ ទៅតាមទំហំនៃការខូចខាតជាក់ស្ដែង។

### ២.២. អគារមានកម្ពស់ចាប់ពីជាន់ទី៩ ដល់ជាន់ទី១១

- ត្រូវអនុវត្តតាមអនុក្រឹត្យលេខ ៤២ ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន និងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា៣០ មាត្រា៣៤ មាត្រា៣៨ មាត្រា៥០ មាត្រា៦៦ មាត្រា៧៤ និងមាត្រា៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន។

## ៦. បែបបទនៃការផ្ដល់លិខិតអនុញ្ញាតសាងសង់

- ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត លើទីតាំងដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់នៅអង្គភាពច្រកចេញ-ចូលតែមួយ នៃរដ្ឋបាលរាជធានី ខេត្ត។ អង្គភាពច្រកចេញ-ចូលតែមួយ ត្រូវបញ្ជូនសំណុំឯកសារទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី ខេត្ត ដើម្បីបំពេញបែបបទតាមនីតិវិធីរៀបចំប្លង់ស្ថាបត្យកម្ម និងរបាយការណ៍បច្ចេកទេស ដាក់ជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ដើម្បីពិនិត្យ និងសម្រេច។
- ចំពោះសំណង់ស្ថិតក្រោមសមត្ថកិច្ចរបស់អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ លើទីតាំងដីដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ម្ចាស់សំណង់ត្រូវដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់នៅការិយាល័យច្រកចេញ-ចូលតែមួយ នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ។ ការិយាល័យច្រកចេញ-ចូលតែមួយ ត្រូវបញ្ជូនសំណុំឯកសារទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីបំពេញបែបបទតាមនីតិវិធី រៀបចំប្លង់ស្ថាបត្យកម្ម និងរបាយការណ៍បច្ចេកទេសដាក់ជូនអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យ និងសម្រេច។

ទទួលបានសារាចរនេះ គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវផ្សព្វផ្សាយ និងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃចន្ទ ៥កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**សាយ សំអាល់**

**កន្លែងទទួល ៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យ**សម្ដេចមហាបវរធិបតីនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួង
- គ្រប់នាយកដ្ឋានជំនាញពាក់ព័ន្ធ ក្រោមឱវាទក្រសួង
- រដ្ឋបាលរាជធានី-ខេត្ត
- គ្រប់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានី-ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ